# សេចក្តីថ្លែងការណ៍

## "សេចក្តីសម្រេចរបស់គណៈកម្មការសហភាពអឺរ៉ុបជះឥទ្ធិពលទៅលើជីវភាពរស់នៅរបស់កម្មករកម្ពុជា គឺជាយន្តការដែលមិនសមស្របក្នុងការដោះស្រាយក្តីព្រួយបារម្ភអំពីស្ថានភាពនយោបាយឡើយ"

រាជធានីភ្នំពេញ៖ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) សូមសម្តែងការខកចិត្ត និងក្តីបារម្ភរបស់ខ្លួនយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចរបស់គណៈកម្មការសហភាពអឺរ៉ុបដែលបានដកផ្នែកខ្លះនៃកម្មវិធី "អនុគ្រោះពន្ធលើគ្រប់មុខទំនិញ លើកលែងតែគ្រឿងសព្វាវុធ (EBA) " សម្រាប់កម្ពុជាដែលបានប្រកាសជាផ្លូវការនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០។ ដូចអ្វីដែលសហព័ន្ធបានលើកឡើង វាគឺជាជំហររបស់យើងដែលបានចាត់ទុកការសម្រេចចិត្តនេះថានឹងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជនដែលសហភាពអឺរ៉ុបនិយាយដោយផ្ទាល់ខ្លួនឯងថានឹងផ្តល់ការគាំទ្រ។ ខណៈពេលដែលមានការងារនៅសេសសល់ដែលត្រូវដោះស្រាយក្នុងការអភិវឌ្ឍក្របខ័ណ្ឌនយោបាយរបស់កម្ពុជាបន្ទាប់ពីត្រូវបានកសាងឡើងវិញក្រោយសង្គ្រាមអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ យើងមិនគិតថានេះគឺជាមធ្យោបាយដ៏សមស្របមួយដើម្បីសម្រេចបាននូវការបញ្ចប់ការងារទាំងនេះនោះទេ ។

កម្ពុជាបានត្រួសត្រាយផ្លូវពាណិជ្ជកម្ម និងសិទ្ធិការងារតាមរយៈកិច្ចសហប្រតិបត្តិការរយៈពេលវែងយ៉ាងពេញលេញជាមួយនិងកម្មវិធីត្រួតពិនិត្យលក្ខខណ្ឌការងាររបស់អង្គការអន្តរជាតិខាងការងារ(ILO) ដោយហៅថា គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា(BFC)។ បច្ចុប្បន្ន កម្មវិធីនេះបានក្លាយជាមូលដ្ឋាននៃការផ្តួចផ្តើមកម្មវិធីសាកលដែលមានឈ្មោះថាកម្មវិធីការងារកាន់តែប្រសើរ - Better Work ។ វាបានកើតចេញការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវកម្មវិធីបែបនេះនៅក្នុងឧស្សាហកម្មផលិតកម្មរបស់ខ្លួន (ជាចម្បងសម្រាប់វិស័យវាយនភណ្ឌ) ដើម្បីការពារកម្មករ និងកសាងវិស័យផលិតកម្មប្រកបដោយចីរភាព ។

ការបាត់បង់អត្ថប្រយោជន៍នៃកម្មវិធីអនុគ្រោះពន្ធ EBA នៅក្នុងស្ថានភាពបច្ចុប្បន្ននឹងធ្វើឲ្យធ្លាក់ចុះនូវគុណតម្លៃ និងភាពសំខាន់នៃគម្រោងកម្មវិធីការងារសកល និងប្រកបដោយវឌ្ឍនភាពមួយនេះ ។ លើសពីនេះ ការបាត់បង់ការងារដែលនឹងកើតមានឡើង នឹងនាំឲ្យមានមនុស្សជាច្រើនវិលត្រលប់ទៅរកភាពលំបាកយ៉ាងខ្លាំងបន្ទាប់ពីបានខិតខំបង្កបង្កើនជីវភាពរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ រួមទាំងការបន្តទទួលបានសេវាថែទាំសុខភាពដ៏សំខាន់តាមរយៈការអនុវត្តប្រព័ន្ធសន្តិសុខសង្គមរបស់យើងនាពេលកន្លងទៅនេះ ។

ទោះបីជាមានការសម្រេចចិត្តនេះក្តី CAMFEBA និងសមាជិករបស់ខ្លួននៅតែប្តេជ្ញាចិត្តចំពោះកម្ពុជា និងធ្វើអ្វីដែលយើងអាចធ្វើទៅបានដើម្បីកាត់បន្ថយផលប៉ះពាល់នៃការដកកម្មវិធីអនុគ្រោះពន្ធមួយនេះ និងជួយជ្រោមជល់កម្មករ ព្រមទាំងវិស័យផលិតកម្មរបស់កម្ពុជាឱ្យមានការរីកចម្រើនបន្តទៅមុខទៀត និងកាន់តែសម្បូរបែប។ យើងស្នើសុំឱ្យអ្នកបញ្ជារទិញ

នៅក្នុងវិស័យដែលរងផលប៉ះពាល់ ពិនិត្យមើលលទ្ធភាពក្នុងការធ្វើពិពិធកម្មនៃការដាក់បញ្ជារទិញនៅក្នុងកម្ពុជាដើម្បីរក្សាបាននូវកម្រិតការងារកម្មកររបស់យើង។ យើងលើកទឹកចិត្តដល់ម្ចាស់រោងចក្រ និងកម្មករទាំងអស់ឱ្យរួមសហការយ៉ាងជិតស្និទ្ធនៅក្នុងប៉ុន្មានសប្តាហ៍ខាងមុខនេះដើម្បីរក្សាបានសន្តិភាព និងស្ថេរភាពនៃបរិយាកាសសេដ្ឋកិច្ចឲ្យមានភាពប្រក្រតី។ ម្យ៉ាងវិញទៀត យើងក៏ស្នើសុំរាជរដ្ឋាភិបាលមានវិធានការឲ្យបានឆាប់រហ័ស និងច្នៃប្រឌិតក្នុងការអនុវត្តនៃការគាំទ្រផ្នែកហិរញ្ញវត្ថុជូនដល់និយោជក និងកម្មករដែលកំពុងរងផលប៉ះពាល់ ។

ខណៈពេលដែលរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនៅក្នុងវិស័យកំពុងព្យាយាមរៀបចំនូវគំនិតផ្តួចផ្តើមផ្សេងៗក្នុងការកាត់បន្ថយផលប៉ះពាល់នៃការដកកម្មវិធីអនុគ្រោះពន្ធនេះ CAMFEBA ក៏សូមគាំទ្រយ៉ាងពេញទំហឹងចំពោះសេចក្តីប្រកាសព័តមានរបស់សមាគមរោងចក្រកាត់ដេរកម្ពុជា(GMAC) និងសូមជំរុញឲ្យគណៈកម្មការសហភាពអឺរ៉ុប និងសមាជិកសភាអឺរ៉ុបឲ្យមានការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចក្នុងការដកនូវឯកសិទ្ធិនៃកម្មវិធីអនុគ្រោះពន្ធ ធ្វើជាយន្តការក្នុងការសម្រេចគោលដៅផ្នែកនយោបាយ។

**អំពីយើង៖**

CAMFEBA បានបង្កើតឡើងក្នុងឆ្នាំ២០០០ ជាជំបូលផ៍ត្រសមាគមនិយោជកកម្ពុជាតែមួយគត់ដែលធ្វើការផ្តោតសំខាន់ទៅលើបញ្ហាការងារ និងសង្គមនៅក្នុងប្រទេសកម្ពុជា ។ យើងសម្របសម្រួល និងតំណាងឲ្យវិស័យធំៗទាំងអស់ដែលមាននៅក្នុងកម្ពុជាតាមរយៈសមាជិកភាពនៃសមាជិកប្រភេទសហគ្រាសអាជីវកម្ម និងវិស័យពាក់ព័ន្ធ សភាពាណិជ្ជកម្ម និងសមាគមវិជ្ជាជីវៈ។ យើងត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិខាងការងារ(ILO) ថាជាសមាសភាពនិយោជករបស់កម្ពុជា ។ CAMFEBA ក៏ជាសមាជិករបស់អង្គការនិយោជកអន្តរជាតិ( IOE ) សហភាពនិយោជកអាស៊ាន (ACE) និងសហភាពនិយោជកអាស៊ីប៉ាស៊ីហ្វិក (CAPE) ។

ភ្នំពេញ កម្ពុជា ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២០
សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ( **CAMFEBA** )
ជាតំណាងឲ្យនិយោជកនៅគ្រប់កាលៈទេសៈ!

សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
CAMBODIAN FEDERATION OF EMPLOYERS & BUSINESS ASSOCIATIONS

សម្រាប់ពត៌មានបន្ថែមអាចទំនាក់ទំនងសមាជិកក្រុមប្រឹក្សាភិបាលយើង
ឧកញ៉ាបណ្ឌិត ណាង សុធី (ភាសាខ្មែរ) +៨៨៥ ១២ ៨០៨ ៩៩៨
លោក ម៉ាធូ វេនឌល (ភាសាអង់គ្លេស) ) +៨៨៥ ១០ ៨៩០ ៦៣២

## Press Release

**EU Commission's decision impacting Cambodian workers' livelihoods an unjust approach to addressing its political space concerns.**

**Phnom Penh, Cambodia: The Cambodian Federation of Employers and Business Associations (CAMFEBA) wishes to register its considerable disappointment and concern at the decision of the European Commission to partially withdraw Cambodia's EBA tariff benefits as announced on 12 February 2020.** As we have previously stated, it is our position that this decision will adversely affect the very people that the Commission seeks, by its own words, to support. Whereas there remains work to be done in the development of Cambodia's political framework - after years of post-war rebuilding - we do not believe that this is an appropriate way to achieve that end.

Cambodia pioneered trade and progressive labour rights through its long-time full cooperation with the International Labour Organization (ILO) labour monitoring program, Better Factories Cambodia (BFC). Today the program is a global initiative called Better Work. It has been the Cambodian Government leadership which has steadfastly pursued mandatory enforcement of such programs in its manufacturing (primarily garment) industries, to protect workers and build a sustainable manufacturing sector.

The loss of EBA benefits in its current context undermines the value and importance of such global and progressive labour programs. In addition, the loss of jobs that will follow will also lead to a return of great hardship for many, after years of steadily increasing livelihoods - including important access to health care services through our recently implemented Social Security Systems.

Despite this decision, CAMFEBA and its members remain committed to Cambodia and doing what we can to negate the effects of the withdrawal and assist Cambodia's workers and manufacturing sector to continue to thrive and diversify. We ask buyers in the affected sectors to look at diversification of order placement in Cambodia to maintain job levels. We encourage factory owners and workers to engage in close cooperation in the coming weeks to maintain peace and stability of the economic environment. We ask the Royal Government to be swift and innovative in its implementation of fiscal support to the sector's employers and workers.

Notwithstanding the government and sector initiatives to negate the effects of this withdrawal, along with the Garment Manufacturers Association of Cambodia (GMAC), who's Press Release we fully endorse, CAMFEBA urges the European Commission and members of the European Parliament to reconsider this decision to withdraw the EBA privileges as a method of achieving political aims.

----

Who we are: Established in 2000, CAMFEBA is Cambodia's sole umbrella employers association working exclusively on labour and social-affairs related matters in Cambodia. CAMFEBA coordinates and represents all major industries in Cambodia through its membership of individual members and respective industry, chamber and professional associations. CAMFEBA is recognized by the Royal Government and the ILO as the employer constituent of Cambodia. CAMFEBA is also a member of the International Organization of Employers (IOE), The ASEAN confederation of Employers (ACE) and the Confederation of Asia Pacific Employers (CAPE).

Phnom Penh, Cambodia, 17 February 2020
Cambodian Federation of Employers and Business Associations (CAMFEBA)
Representing employers where it matters most!

CAMBODIAN FEDERATION OF EMPLOYERS & BUSINESS ASSOCIATIONS

**For enquiries Contact our Board of Directors**
Okhna Dr. Nang Sothy, (Khmer) – +855 12 808 998
Matthew Rendall, (English) – +855 10 890 632